**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...១៦៤.......អ.ន.ក


ថ្ងៃ.សុក្រ ១០ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** : របាយការណ៍ប្រចាំខែមករា ស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងលទ្ធផលបញ្ចប់ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៧ " គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ "។

**ជូនភ្ជាប់** : របាយការណ៍លំអិតប្រចាំខែមករា ស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងលទ្ធផលបញ្ចប់ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៧ " គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ " ចំនួន ០១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងលទ្ធផលបញ្ចប់ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៧ " គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ " សម្រេចបាន:

**១. ការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ :**

**ក. ដំណាំស្រូវ** : ស្ទូង និងព្រោះអនុវត្តបានចំនួន ៤៧៣.៦៩៧ ហ.ត ស្មើនឹង ១០៦,៧៦% នៃផែនការ ចំនួន ៤៤៣.៧០០ ហ.ត ល្បឿនជាងឆ្នាំមុន ២៣.១៧៩ ហ.ត

**ខ. ដំណាំរួមផ្សំ** : អនុវត្តបាន ៧៣.១៥១ ហ.ត ល្បឿនជាងឆ្នាំមុន ៦៨៥ ហ.ត

**គ. ដំណាំឧស្សាហកម្ម** : អនុវត្តបាន ១៣.៦៥០ ហ.ត យឺតជាងឆ្នាំមុន ១.៣០៨ ហ.ត

**២. លទ្ធផលបញ្ចប់ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៧ :**

កសិករតាមបណ្តាខេត្ត-រាជធានីបានបានបញ្ចប់ការងារប្រមូលផលស្រូវរដូវវស្សាលើផ្ទៃដី ២.៦៤១.៦៣៧ ហ.ត ស្មើនឹង១០០% នៃផ្ទៃដីដែលត្រូវប្រមូលផលដោយទទួលបានទិន្នផលមធ្យម ៣,០៥៦ តោន/ហ.ត និងបរិមាណផលសរុប ៨.០៧១.៨៣៤ តោន។

អាស្រ័យហេតុដូចបានគោរពជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហ៊ាន វណ្ណហាន**

**ចំលងជូន ៖**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីគោរពជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានពាក់ព័ន្ធរបស់អគ្គនាយកដ្ឋានកសិកម្ម
- ឯកសារ កាលប្បវត្តិ


អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427